D24303
(DC-Cam)

កម្ពុជាប្រជាធិបតេយ្យ

គណៈប្រធានរដ្ឋ

ក្រមលេខ : ក ជ ប ត ៧៦ - ១

# ក្រម

## កំណត់របៀបរបបធ្វើការងាររបស់សភាតំណាងប្រជាជនកម្ពុជា និងគណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា

ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ

- ដោយយោងទៅតាមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ដែលមហាសន្និបាតជាតិលើកទី ៣ បានអនុម័តកាលពីថ្ងៃ ១៤ ធ្នូ ឆ្នាំ ១៩៧៥

- ដោយយោងទៅតាមសេចក្ដីសំរេចរបស់សភាតំណាងប្រជាជនកម្ពុជាក្នុងសន្និបាតពេញអង្គលើកទី ១ ក្នុងកាលសម័យលើកទី ១ ដែលបានធ្វើពីថ្ងៃ ១១ មេសា ដល់ថ្ងៃ ១៣ មេសា ឆ្នាំ ១៩៧៦ តែងតាំងគណៈប្រធានរដ្ឋ

- ដោយយោងទៅតាមសេចក្ដីសំរេចរបស់សភាតំណាងប្រជាជនកម្ពុជាក្នុងសន្និបាតពេញអង្គលើកទី ១ ក្នុងកាលសម័យលើកទី ១ ដែលបានធ្វើពីថ្ងៃ ១១ មេសា ដល់ថ្ងៃ ១៣ មេសា ឆ្នាំ ១៩៧៦ កំណត់របៀបរបបធ្វើការងាររបស់សភាតំណាងប្រជាជនកម្ពុជា និងគណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា

ប្រកាសឱ្យប្រើប្រាស់នូវក្រមដែលមានខ្លឹមសារដូចតទៅ ៖

.... ២

# I

## អំពីសភាតំណាងប្រជាជនកម្ពុជា

-០០-

មាត្រា ១ - សមាជិករបស់សភាតំណាងប្រជាជនកម្ពុជាមួយរូបៗ ត្រូវស្ថិតនៅជិតស្និទ្ធ ក្នុងមូលដ្ឋានរបស់ខ្លួនតទៅទៀត ត្រូវរួមសុខរួមទុក្ខជាមួយប្រជាជន ស្តាប់ចិត្តស្តាប់មតិប្រជាជន ក្តាប់សំណូមពរប្រជាជន ពោលគឺនៅជាប់នឹងសហជីព នឹងរោងចក្រ នៅជាប់នឹងសហករណ៍ ការដ្ឋាន ប្រព័ន្ធភ្លឺ និងប្រឡាយទឹក នៅជាប់នឹងអង្គភាពរបស់ខ្លួន រួមសកម្មភាពការពារប្រទេស និងកសាងប្រទេសជាមួយប្រជាជនកម្មករ និងកសិករ ពលករដទៃទៀត យុវជន យុវនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តកម្ពុជាតទៅទៀត ដើម្បីឱ្យយល់ច្បាស់នឹងបញ្ហារបស់ខ្លួន ជាតំណាងពិតប្រាកដរបស់ប្រជាជនកម្ពុជា និងកសិករ ពលករដទៃទៀត និងកងទ័ពបដិវត្តកម្ពុជា ។

មាត្រា ២ - សភាតំណាងប្រជាជនកម្ពុជា បើកសម័យប្រជុំពេញអង្គធម្មតាមួយឆ្នាំ ១ ដង ដើម្បី :

- ធ្វើ និងអនុម័តច្បាប់
- លើកមាគ៌ានយោបាយក្នុងប្រទេស ក្រៅប្រទេសប្រចាំឆ្នាំ
- ពិនិត្យតាមដានសកម្មភាពរបស់គណៈប្រធានរដ្ឋ រដ្ឋាភិបាល និង គណៈកម្មាធិការតុលាការ ពិនិត្យគុណសម្បត្តិ និងការខុសខាតរបស់អង្គការរដ្ឋទាំង ៣ នេះ និងតំរែតំរង់ការងារប្រចាំឆ្នាំ របស់អង្គការរដ្ឋទាំង ៣ នេះ ។

មាត្រា ៣ - ក្នុងករណីពិសេស សភាតំណាងប្រជាជនកម្ពុជាអាចបើកសន្និបាតពេញអង្គពិសេស តាមការស្នើសុំរបស់ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា ។

មាត្រា ៤- សភាតំណាងប្រជាជនកម្ពុជាអាចបើកសន្និបាតពេញអង្គបាន លុះត្រាតែមានសមាជិក យ៉ាងតិចជាងពាក់កណ្ដាលចូលរួម ។

មាត្រា ៥- រឿងបញ្ហាសំខាន់ៗ ជានយោបាយក្នុងប្រទេស ក្រៅប្រទេស ការសំរេចរបស់សភាតំណាងប្រជាជនកម្ពុជានឹងសន្មតជាបានការ លុះត្រាតែមានសំឡេងភាគច្រើនដាច់ខាតនៃសមាជិកសភាទាំងមូល ។

មាត្រា ៦- សភាតំណាងប្រជាជនកម្ពុជាមានសិទ្ធិពេញទីក្នុងការកំណត់ តើបញ្ហាណាជាបញ្ហាសំខាន់ ។

មាត្រា ៧- សន្ធិសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងជាមួយប្រទេសណាមួយ នឹងសន្មតជាបានការ លុះត្រាតែបានទទួលការអនុម័តពីសភាតំណាងប្រជាជនកម្ពុជា ដោយសំឡេងភាគច្រើនដាច់ខាត ។

## II

### អំពីគណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា

-------------

មាត្រា ៨- ក្នុងរយៈកាលពីសន្និបាតពេញអង្គមួយ ទៅសន្និបាតពេញអង្គមួយ របស់សភាតំណាងប្រជាជនកម្ពុជា មានអង្គការប្រចាំការមួយរបស់សភាតំណាងប្រជាជនកម្ពុជា ទទួលភារកិច្ចអនុវត្ត និងតាមដានការអនុវត្តសេចក្ដីសំរេចចិត្តផ្សេងៗរបស់សន្និបាតពេញអង្គរបស់សភាតំណាងប្រជាជនកម្ពុជា និងរៀបចំឯកសារសំរាប់សន្និបាតពេញអង្គរបស់សភាតំណាងប្រជាជនកម្ពុជាអនុម័ត ។ អង្គការប្រចាំការរបស់សភានេះ មានឈ្មោះថា គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា ។

..../

មាត្រា ៩ - គណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា មាន ១០ រូប :

- ប្រធាន ១ រូប
- អនុប្រធានទី ១ ១ រូប
- អនុប្រធានទី ២ ១ រូប
- សមាជិក ៧ រូប

ប្រធានសភាតំណាងប្រជាជនកម្ពុជា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា ។

មាត្រា ១០ - គណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា ត្រូវជ្រើសតាំងឡើងតាមការបោះឆ្នោតដោយសម្លេងភាគច្រើនដាច់ខាត ។

## III

## អំពីកាលៈទេសៈពិសេសដែលរាំងរាមិនឱ្យ
## សភាតំណាងប្រជាជនកម្ពុជាដំណើរការធម្មតា

---------

មាត្រា ១១ - ក្នុងសភាពការណ៍ពិសេសដែលរាំងរាមិនឱ្យសភាតំណាងប្រជាជនកម្ពុជាដំណើរការទៅតាមធម្មតាបាន ដូចជាពេលមានសង្គ្រាមជាដើម :

- សភាតំណាងប្រជាជនកម្ពុជា អាចប្រជុំនៅទីកន្លែងណាមួយទៀតផ្សេងក្រៅពីរដ្ឋធានីភ្នំពេញ នៅក្នុងប្រទេសកម្ពុជា តាមការកំណត់របស់គណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា ។
- ក្នុងករណីដែលសភាពការណ៍មិនអនុញ្ញាតិឱ្យចាត់តាំងបោះឆ្នោតតាមការកំណត់បាន សភាតំណាងប្រជាជនកម្ពុជា អាចបំពេញបន្តអាណត្តិរបស់ខ្លួន រហូតដល់សភាពការណ៍ធម្មតាឡើងវិញ និងរហូតដល់មានការបោះឆ្នោតឡើងវិញ ។

- ពេលនោះ ក្នុងករណីចាំបាច់ សភាតំណាងប្រជាជនកម្ពុជា អាចប្រគល់ការកិច្ចជូនគណៈកម្មាធិការអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា ដំណើរការទៅជាអង្គការនីតិបញ្ញត្តិ ក្នុងនាមសភាតំណាងប្រជាជនកម្ពុជា ក្នុងមួយរយៈពេលដែលសភាតំណាងប្រជាជនកម្ពុជា នឹងកំណត់ ។

មាត្រា ១២- ក្រមនេះ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃនេះទៅ ។

ភ្នំពេញ ថ្ងៃ ២ ឧសភា ឆ្នាំ ១៩៧៦

គណៈប្រធានរដ្ឋ

ខៀវ សំផន

ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ

៨៦

តទៅ :

**Democratic Kampuchea** (DC-Cam File Number D24303)
----------------------------

**The State Presidium**

Kram no.: ក ជ ប ត ៧៦-១

**KRAM**

**On the Determination of the Functioning of the People's Representative Assembly of Kampuchea and the Standing Committee of the People's Representative Assembly of Kampuchea.**

………….

The President of the State Presidium of Democratic Kampuchea,

basing on the constitution of Democratic Kampuchea adopted by the third National Congress on 14 December 1975, the Decision of the People's Representative Assembly of Kampuchea in the first Plenary Session of the First Legislature, which seated from 11-13 April 1976 on the appointment of the State Presidium, and the Decision of the Kampuchean People's Representative Assembly in the first Plenary Session of the First Legislature on the functioning of the Kampuchean People's Representative Assembly and the Standing Committee of the Kampuchean People's Representative Assembly adopted from 11-13 April 1976,

hereby promulgates the Kram with the following substance:

**I. On the People's Representative Assembly of Kampuchea:**

Article 1: Each of the Kampuchean People's Representative Assembly members must continue to stay close to his/her grassroot, sharing their difficulties and happiness, knowing peoples' hearts, understanding their requests, that is, remaining close with unions and factories, cooperatives, work sites, irrigation systems, his/her unit, by sharing efforts to build and defend the country with the people, workers and farmers, laborers, male and female combatants and cadres of the Kampuchean Revolutionary Army in order to balance their status as real representatives of Kampuchean people, farmers, laborers and Revolutionary Army.

Article 2: The Kampuchean People's Representative Assembly shall open its plenary, regular session once a year for the purpose of:

- Making and adopting laws
- Proposing annual policies—domestic and foreign
- Examining and following up the activities of the President of State Presidium, the Government and Judicial Committee, and examining

the quality and shortfall of the three State organs and re-orienting the annual work of these three organs.

Article 3: In special cases, the People's Representative Assembly can open a special plenary session as invited by the President of the Standing Committee of the Kampuchean People's Representative Assembly.

Article 4: The Kampuchean People's Representative Assembly shall not open a plenary session unless there is a quorum of fifty percent.

Article 5: Decisions on important matters regarding domestic and foreign policies shall be valid unless by an absolute majority of the Kampuchean People's Representative Assembly

Article 6: The Kampuchean People's Representative Assembly shall have the full right to determine major issues.

Article 7: International treaties and agreements with a particular country shall be valid as long as they are adopted by an absolute majority vote by the Kampuchean People's Representative.

## II. On the Standing Committee of the Kampuchean People's Representative Assembly

Article 8: In between a plenary session of the Kampuchean People's Representative Assembly, there shall be a standby organ of the Assembly to implement and to follow up the decisions made by the plenary session of the Assembly and to prepare documents for the plenary session of the Assembly to adopt. The standby organ is called the Standing Committee of the Kampuchean People's Representative Assembly.

Article 9: The Standing Committee of the Kampuchean People's Representative Assembly consists of 10 members:

. One Chairman
. One First Deputy
. One Second Deputy
. Seven Members

The president of the Kampuchean People's Representative Assembly shall be the chairman of the Standing Committee of the Kampuchean People's Representative Assembly.

Article 10: The Standing Committee of the Kampuchean People's Representative shall be elected by an absolute majority vote.

## III. On special circumstances where the Kampuchean People's Representative Assembly is unable to operate

Article 11: In special circumstances which prevent the Kampuchean People's Representative Assembly from functioning normally, such as in a time of war:

. The People's Representative Assembly of Kampuchea shall open its session in another place in Kampuchea other than in the Capital City of Phnom Penh to be determined by the Standing Committee of the Kampuchean People's Representative Assembly.

. In circumstances where an election cannot take place as scheduled, the Kampuchean People's Representative Assembly shall continue its mandate until the situation becomes normal and a re-election occurs. In this situation, if necessary, the Kampuchean People's Representative Assembly can delegate its duty to the Standing Committee of the People's Representative Assembly that converts itself into the legislature in the name of the Kampuchean People's Representative Assembly for a period of time to be determined by the People's Representative Assembly of Kampuchea.

Article 12: This Kram shall be implemented from today onward.

Phnom Penh, 2 May 1976

(Signed and sealed)

Khieu Samphan
President of the State Presidium